**សេដាកប្រារព្ធទិវាអ្នកបរិភោគ ពិភពលោក "World Consumer Day" :** នៅប្រទេសកម្ពុជា អង្គការសេដាក បានរៀបចំនូវសកម្មភាពមួយចំនួនដូចជា ការផ្សព្វផ្សាយតាមកម្មវិធីវិទ្យុ ទូរទស្សន៍ សិក្ខាសាលា និងការតាំងពិពណ៌អង្ករសរីរាង្គជាដើម ដែលជាផ្នែកនៃសកម្មភាព "កូរ៉ា" នៅអាស៊ី។



ជាពិសេសនៅ**ថ្ងៃទី ១៥ ខែមីនា ឆ្នាំ ២០១១** អង្គការសេដាកនឹងរៀបចំ អបអរសាទរ **ទិវាអ្នកបរិភោគ ពិភពលោក** "World Consumer Day" ក្រោមប្រធានបទ **"សុវត្ថិភាពស្រូវ-អង្ករសំរាប់សុខភាព និងមុខរបរ ចិញ្ចឹមជីវិត"** នៅការិយាល័យកណ្តាល អង្គការសេដាក។ អ្នកចូលរួមសរុបមានចំនួន ៨៤ នាក់ដែលរួមមានកសិករ សិស្សនិស្សិត អ្នកសារព័ត៌មាន អ្នកជំនាញខាងម្ហូបអាហារ និងតំណាងមន្ត្រីរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលពាក់ព័ន្ធមួយចំនួន។

គួរជំរាបជូនថា កូរ៉ា (Collective Rice Action) ឬ សកម្មភាពរួមគ្នាសម្រាប់ដំណាំស្រូវ ជាសកម្មភាពថែរក្សា និងការពារពូជស្រូវ របស់កសិករ និងជម្រុញនូវការផលិត និងបរិភោគស្រូវ-អង្ករផលិតតាមគោលការណ៍ធម្មជាតិ។